# លិខិតចំហររបស់អង្គការសង្គមស៊ីវិល

## សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

យើងខ្ញុំជាអង្គការសង្គមស៊ីវិល ដែលរួមមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា សូមសម្តែង នូវការកោតសរសើរ ដ៏ខ្ពង់ខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងសង្គមស៊ីវិល ដែលជាកត្តាសំខាន់មួយនៅក្នុងការអភិវឌ្ឍកម្ពុជា ពីប្រទេសមួយដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម មកជាប្រទេសកំពុងអភិវឌ្ឍន៍ ប្រកបដោយសន្តិភាពយ៉ាងរស់រវើក។ បើទោះបីជាមានគំនិតយោបល់ខុសគ្នា មួយចំនួនកន្លងមកក៏ដោយ តាមរយៈកិច្ចពិភាក្សាបែបស្ថាបនា រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល មានចំណុចឯកភាពគ្នាដែលទទួលបានលទ្ធផលជាច្រើនប្រកបដោយការយោគយល់គ្នា និងសហប្រតិបត្តិការល្អ។

ដោយមានការទទួលស្គាល់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាកន្លងមកនេះ អង្គការសង្គមស៊ីវិលបានដើរតួនាទីជាដៃគូសំខាន់ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ សំណៅបច្ចុប្បន្នភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩ បានលើកឡើងថា "អង្គការសង្គមស៊ីវិលជាដៃគូសំខាន់មួយ ហើយអង្គការមិនមែនរដ្ឋាភិបាលរួមទាំងថ្នាក់ជាតិ និងអន្តរជាតិជាច្រើនទៀតក៏ដើរតួនាទីយ៉ាងសកម្ម និងយ៉ាងយកចិត្តទុកដាក់ចំពោះកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចព្រមទាំងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សផងដែរ។"

នាពេលថ្មីៗនេះសមាជិកនៃគណៈកម្មការរដ្ឋសភាពបានសុំយោបលពីសំណាក់អង្គការសង្គមស៊ីវិលកម្ពុជាពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដើម្បីជាជំហរចំពោះផ្នែកផ្សេងៗនៃសេចក្តីព្រាងច្បាប់ដែលរួមមានទាំងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងសេចក្តីព្រាងច្បាប់ស្តីពីគ្រប់គ្រងអង្គការ និងសមាគមន៍ ដែលយើងមានការព្រួយបារម្ភថាអាចនឹងធ្វើឲ្យមានការកាត់បន្ថយឱកាសសម្រាប់ការចូលរួមរបស់សង្គមនៅក្នុងអភិបាលកិច្ចព្រមទាំងបង្អាក់សិទ្ធិមនុស្សដែលពាក់ព័ន្ធផងដែរ។ យើងត្រូវបានចោទសួរថាតើយើងគ្រាន់តែប្រឆាំងនឹងច្បាប់ទាំងនេះ ឬគាំទ្រឲ្យមានការកែលម្អដោយលើកជាវិសោធនកម្មផ្សេងៗឬយ៉ាងណា។ ដោយពិចារណាលើសំណួរនេះ អាចសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា ប្រសិនបើមិនបានឃើញទម្រង់ផ្លូវការថ្មីៗនៃសេចក្តីព្រាងច្បាប់ទាំងនោះ ជាការលំបាកដើម្បីឲ្យដឹងថាតើយើងអាចគាំទ្របានល្អប្រសើរកម្រិតណាដល់ការបង្កើតគោលនយោបាយរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងកត្តាទាំងនេះណាស់។

ដើម្បីឆ្លើយតបនឹងគណៈកម្មការរដ្ឋសភាប្រកបដោយអត្ថន័យ និងដើម្បីអនុវត្តតួនាទីរបស់យើងប្រកបដោយការទទួលខុសត្រូវក្នុងនាមតំណាងឲ្យភាគីពាក់ព័ន្ធផ្សេងៗដែលជាតំណាងរាស្ត្រ សមាជិក និងអត្ថាគាហក ហើយដើម្បីគាំទ្រដល់មន្ត្រីរាជរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចការដ៏លំបាកនៃការតាក់តែងច្បាប់ដែលបម្រើអត្ថប្រយោជន៍ស្មើគ្នាៗដល់ស្ថាប័នផ្សេងៗ និងសង្គមស៊ីវិលនោះ យើងសូមស្នើសុំឲ្យក្រសួង និងគណៈកម្មាធិការនានាដែលគ្រប់គ្រងសេចក្តីព្រាង បញ្ចេញឯកសារទាំងនេះជាសាធារណៈ។ បញ្ជីសេចក្តីព្រាងច្បាប់ថ្មីៗដែលយើងបានស្នើសុំរួមមានសេចក្តីព្រាង ច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត សេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ សេចក្តីព្រាងច្បាប់ស្តីពីសហជីព សេចក្តីព្រាងច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងសេចក្តីព្រាងច្បាប់ស្តីពីការប្រើប្រាស់ និងគ្រប់គ្រងដីកសិកម្មជាដើម។ ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់មួយចំនួនដូចជាសេចក្តីព្រាងច្បាប់ស្តីពីសហជីពកម្មករជាដើម មានសេចក្តីព្រាងដែលកំពុងលើកយកពិភាក្សា ប៉ុន្តែយើងបានស្នើឲ្យសេចក្តីព្រាងថ្មីៗនេះធ្វើឡើងជាសាធារណៈចំពោះរាល់បញ្ហាទាំងអស់។ លើសពីនេះ យើងក៏បានស្នើសុំឲ្យរដ្ឋាភិបាលប្រកាសជាសាធារណៈនូវរាល់សេចក្តីព្រាងច្បាប់ទាំងអស់មុន

ពេលបញ្ចប់ការពិនិត្យជាស្ថាពររបស់ខ្លួននៅទីស្តីការគណៈរដ្ឋមន្ត្រី ហើយចាត់ទុកថានេះគឺជាទម្លាប់អនុវត្តបទដ្ឋានផងដែរ។

យើងសូមគាំទ្ររាជរដ្ឋាភិបាលចំពោះការពិគ្រោះយោបល់អំពីសេចក្តីព្រាងច្បាប់ទាំងនេះ ហើយនេះជាសកម្មភាពមួយដែលរដ្ឋាភិបាលបានព្រមព្រៀងអនុវត្តផងដែរ។ នៅអំឡុងវដ្តត្រួតពិនិត្យជាប្រចាំជាសកល (UPR) ស្តីពីសិទ្ធិមនុស្ស ឆ្នាំ២០០៩ ប្រទេសកម្ពុជាបានទទួលយកអនុសាសន៍របស់ចក្រភពអង់គ្លេសដែលស្នើឲ្យប្រទេសកម្ពុជា៖ *ពង្រីកដំណើរការពិគ្រោះយោបល់លើការបង្កើតគោលនយោបាយ ការតាក់តែងច្បាប់ និងបទបញ្ញត្តិ ដើម្បីធានាថារាល់លិខិតតូបករណ៍គតិយុត្តិ ត្រូវបានវាយតម្លៃចំពោះផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានលើបញ្ហាសិទ្ធិមនុស្ស។* អនុសាសន៍នេះអនុវត្តចំពោះសេចក្តីព្រាងច្បាប់ទាំងអស់ដែលបានកំណត់ខាងលើ។

អំឡុងពេលដំណើរការត្រួតពិនិត្យជាប្រចាំជាសកលឆ្នាំ២០១៤ ប្រទេសកម្ពុជាបានយល់ព្រមតាមអនុសាសន៍របស់ប្រទេសស៊ុយអែតដែលស្នើថាប្រទេសកម្ពុជាគួរតែ៖ *ដោះស្រាយបញ្ហានិយ័តកម្មសេរីភាពក្នុងការបញ្ចេញមតិលើអ៊ីនធឺណិតតាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់។* លើសពីនេះទៅទៀតនៅក្នុងវដ្តនេះ ប្រទេសកម្ពុជាក៏បានយល់ព្រមតាមអនុសាសន៍របស់ប្រទេសហុងគ្រីផងដែរថា៖ *ស្របតាមការប្តេជ្ញាចិត្តរបស់ខ្លួននៅក្នុងវដ្តត្រួតពិនិត្យជាប្រចាំជាសកលលើកមុន ប្រទេសកម្ពុជានឹងឈានឆ្ពោះទៅរកការធានាសិទ្ធិសេរីភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក និងផ្តល់សិទ្ធិសេរីភាពឲ្យមានវិធានគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក តាមរយៈការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធអ៊ីនធឺណិតស្របតាមបទដ្ឋានអន្តរជាតិ។* ជាមួយគ្នានេះដែរ ចំណុចទាំងនេះបង្ហាញអំពីការប្តេជ្ញាចិត្តជាអន្តរជាតិមួយដែលប្រទេសកម្ពុជានឹងគាំទ្រដល់ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ហើយអនុវត្តការពិគ្រោះយោបល់នេះក្នុងគោលបំណងបង្កើតច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិត (និងច្បាប់ស្តីពីទូរគមនាគមន៍) ដែលបំពេញតាមបទដ្ឋានអន្តរជាតិនៅគ្រប់ទិដ្ឋភាពទាំងអស់។

ដូច្នេះ យើងជាអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ដែលមានចុះហត្ថលេខាខាងក្រោម សូមអំពាវនាវជាសម្ហូភាព ដោយការគោរពចំពោះរាជរដ្ឋាភិបាលកម្ពុជាឱ្យធ្វើការពិចារណាឡើងវិញ ទៅលើសំណើសំខាន់ៗរបស់យើង ជាពិសេសចែករំលែកសេចក្តីព្រាងច្បាប់នានា និងធ្វើការពិគ្រោះយោបល់ជាសាធារណៈ មុនពេលសេចក្តីព្រាងច្បាប់នេះត្រូវបានឯកភាពដោយទីស្តីការគណៈរដ្ឋមន្ត្រី និងអនុម័តដោយរដ្ឋសភាជាតិ។ នេះជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលក្នុងការធានានូវសិទ្ធិទទួលបានព័ត៌មានដល់សាធារណៈជន រួមទាំងអង្គការសង្គមស៊ីវិលផងដែរ។

**<u>Endorsed by</u>**

*<u>Grassroots communities and networks:</u>*

1. Banteay Srei District Land Communities Network (6 communities)
2. Cambodian Grassroots Cross-Sector Network
3. CICA Kampot
4. Chorm Paen Forestry Community, Preah Vihear
5. Coastal Community Fishery Network, Kampot
6. O' Chrov Fishery Community, Preah Sihanouk
7. Farmer Community for Peace and Development, Kampot
8. Kandal Stung District Land Communities, Kandal
9. Independent Farmer Association for Community Development, Prey Veng
10. Independent Farmer and Nature Network (13 provinces)

11. Land Communities Preah Sihankouk City and Province (16 communities)
12. Phnom Kouk Network Pursat
13. Phnom Kouk Network Kompong Chnang
14. Sugar Justice Network, Koh Kong
15. Sahakum Arunras, Leang Dai village, Angkor Thom district, Siem Reap
16. Sahakum Rukhacheat Baitang, Tropaing Svay village, Angkor Thom district, Siem Reap
17. Sahakum StreySmachet Srok Angkor Thom
18. SahakumKapreaSith and Ackpiwat, Khum Yea-ang, Kompong Speu
19. Tonle Sap Fishery Network, KompongChnang
20. TropaingTeumCommnity, PreahVihear

*Organizations (NGOs)*

21. Cooperation Committee for Cambodia (CCC)
22. Cambodia Center for Human Right (CCHR)
23. Cambodian Human Rights Action Committee (CHRAC)
24. Gender and Development for Cambodia (GADC)
25. Transparency International Cambodia (TIC)
26. Banteay Srei Organization
27. Ponleu Ney Kdei Songkhem (PNKS)
28. People's Action for Change (PAC)
29. Cambodia Youth Network (CYN)
30. Legal Support for Children and Women (LSCW)
31. Union Coalition for Labour (UCL)
32. Coalition of Cambodian Farmer Community (CCFC )
33. STAR Kampuchea (SK)
34. Development & Partnership in Action (DPA)
35. NGO Education Partnership (NEP)
36. Advocacy and Policy Institute (API)
37. Cambodian Center for Independent Media (CCIM)
38. Committee for Free and Fair Elections in Cambodia (COMFREL)
39. Cambodian Volunteers for Community Development (CVCD)
40. Rural Development Organization (RDO)
41. MEDiCAM (MEDiCAM)
42. Cambodian Rural Development Team (CRDT)
43. Building Community Voices (BCV)
44. Cambodian League for the Promotion and Defense of Human Rights (LICADHO)
45. Cambodia's Independent Civil-Servant Association (CICA)

*International Organization (INGOs)*

46. Freedom House (FH)
47. Reporters Without Borders (RWB)
48. Dan Church Aid/Christian Aid (DCA/CA)
49. Diakonia Country Office (Cambodia)
50. MoPoTsyo Patient Information Centre (MoPoTsyo)
51. Mekong Plus (Mekong Plus)
52. Youth With A Mission (CAMBODIA) (YWAM)
53. Dignity International
54. Pax Romana ICMICA
55. World Alliance for Citizen Participation (CIVICUS)
56. Aide et Action Cambodia (AetA)